8901 / 54149

BẢN DỊCH
TRANSLATION

**VƯƠNG QUỐC CAMPUCHIA**

**Dân Tộc – Tôn Giáo – Quốc Vương**

# HỢP ĐỒNG SỬA ĐỔI HỢP ĐỒNG ĐÃ KÝ KẾT NGÀY 01/03/2011

**GIỮA**

**BỘ NÔNG, LÂM VÀ NGƯ NGHIỆP**

**VÀ**

**CÔNG TY TRÁCH NHIỆM HỮU HẠN PHÁT TRIỂN CAO SU DẦU TIẾNG (CAMBODIA) DACAMRUCO**

- Tham chiếu hợp đồng đã được ký kết ngày 01/03/2011 giữa Chính phủ Hoàng gia Campuchia và Công ty TNHH phát triển cao su Dầu Tiếng (Cambodia) Dacamruco về việc đầu tư trồng cây cao su tại Huyện Snuol và Huyện Chhluong, trực thuộc Tỉnh Kratie.
- Căn cứ Điều 18 của hợp đồng được ký kết ngày 01/03/2011 giữa Chính phủ Hoàng gia Campuchia và Công ty TNHH phát triển cao su Dầu Tiếng (Cambodia) Dacamruco về việc đầu tư trồng cây cao su tại Huyện Snuol và Huyện Chluong, trực thuộc Tỉnh Kratie.
- Căn cứ Giấy chứng nhận quyền sở hữu bất động sản của Bộ Nông, Lâm và Ngư Nghiệp về định hướng tô nhượng đất kinh tế gồm 19 bản cho Công ty TNHH phát triển cao su Dầu Tiếng (Cambodia) Dacamruco.
- Căn cứ Thông báo số 927-Tb ký kết ngày 14/08/2015 của Văn phòng Hội đồng Bộ trưởng.
- Hai bên thỏa thuận, thống nhất theo các điều khoản như sau:

HỆ
DỊCH THUẬ
Đ/C: 12 Nguyễn

**ĐIỀU 1:**

Sửa đổi Mục 1.1 Điều khoản 1 trong bản hợp đồng cũ ký kết vào ngày 01/03/2011 thành Điều khoản 1 trong bản hợp đồng mới và trở thành mục nội dung trong bản hợp đồng mới. Bên A đồng ý tô nhượng đất kinh tế với tổng diện tích 2549,80 hecta (Hai ngàn năm trăm bốn mươi chín phẩy tám mươi hecta) và là vùng diện tích đất đã hoàn tất việc đăng ký là đất Nhà nước, tọa lạc tại Huyện Snuol và Huyện Chhluong, trực thuộc Tỉnh Kratie cho Bên B sở hữu và sử dụng cho việc đầu tư trồng cây cao su. Diện tích đất này sẽ được phân định rõ ràng trong bản đồ chỉ điểm và danh sách điểm tọa độ, sau đây gọi là "khu vực" và khu vực này có Giấy chứng nhận quyền sở hữu bất động sản kèm theo gắn kèm trong phần phụ lục của bản hợp đồng này.

**ĐIỀU 2 :**

A2Z CONSULTING AND TRANSLATION CO., LTD.
12 Nguyen Phong Sac, Dich Vong, Cau Giay, HN
Tel: 0966.779.888
Ha Noi, 4 / 7 /2022

Trong thời hạn thực hiện hợp đồng, việc bổ sung nội dung trong tất cả các điều khoản được nêu rõ trong hợp đồng này, Bên B phải có bổn phận như sau :

**2.1.** Lập bản quy hoạch tổng thể trên tổng diện tích đất như đã nêu rõ trong Điều khoản 1 chậm nhất 03 (ba) tháng kể từ sau khi ký kết hợp đồng sửa đổi, bổ sung này. Việc sử dụng khu vực đất mới này phải tuân theo bản quy hoạch tổng thể, trong bản quy hoạch tổng thể cần phải nêu rõ : mục đích việc sử dụng khu đất, việc vận dụng kỹ thuật khác, và kế hoạch cân bằng kinh tế, tài chính trong quá trình thực hiện dự án đầu tư. Khi nào Bên A chấp thuận với các nội dung đã nêu trong bản quy hoạch tổng thể trước thì Bên B mới có quyền bắt đầu đưa vào hoạt động.

**2.2.** Để thực hiện một cách sao cho có hiệu quả theo tiến trình đầu tư dự án trong khu vực tô nhượng đất kinh tế và đảm bảo cho việc quản lý, kiểm tra, đánh giá thì Bên B phải lập kế hoạch hoạt động thường niên hàng năm rõ ràng. Kế hoạch hoạt động này phải được gửi đến Bộ Nông, Lâm và Ngư Nghiệp trước ít nhất 30 (ba mươi) ngày, kể từ ngày Công ty gửi yêu cầu xin phép phát quang trồng trọt ở các tiểu vùng tiếp theo.

## ĐIỀU 3 : VỀ THỜI HẠN

Sửa đổi Điều khoản số 4 trong bản hợp đồng cũ ký kết ngày 01/03/2011 thành Điều khoản số 3 trong bản hợp đồng mới, gồm các nội dung như sau :

**3.1.** Hợp đồng này có thời hạn 50 năm. Tính kể từ ngày ký kết hợp đồng ban đầu vào ngày 01/03/2011, việc thông báo kết thúc hợp đồng phải được báo trước 01 (một) năm hoặc trong năm cuối cùng của hợp đồng.

**3.2.** Bên B có quyền xin tiếp tục gia hạn hợp đồng sau thời hạn 50 năm, trong khoảng thời gian 01 năm trước khi hợp đồng hết hiệu lực, Bên B có quyền yêu cầu xin tiếp tục thực hiện dự án đầu tư, và việc yêu cầu tiếp tục gia hạn hợp đồng sẽ được thực thi trong trường hợp nhận được Chủ trương cho phép từ phía Chính phủ Hoàng gia Campuchia theo lời đề nghị của Bên A, căn cứ vào những gì mà Bên B đã thực hiện được, nhờ sự ủng hộ từ khu vực tô nhượng đất kinh tế đã mang lại lợi ích kinh tế, xã hội của cả hai bên và bởi sự cố gắng học tập và chấp thuận từ Bên A về các điều khoản trong bản hợp đồng mới này. Trong trường hợp không yêu cầu xin tiếp tục gia hạn hợp đồng, Bên A có quyền thực hiện chuyển nhượng hợp đồng đầu tư cho Bên thứ 3.

## ĐIỀU 4 : VIỆC CHUYỂN NHƯỢNG

Sửa đổi Điều khoản số 10 trong bản hợp đồng cũ ký kết ngày 01/03/2011 thành Điều khoản số 4 trong bản hợp đồng mới, gồm các nội dung như sau :

Bên B không được phép chuyển nhượng hợp đồng cho Bên thứ 3, trừ trường hợp pháp luật cho phép hoặc nhận được sự chỉ đạo khác từ phía Chính phủ Hoàng gia. Nhưng Bên A được phép hợp tác vốn đầu tư với thể nhân và pháp nhân khác căn cứ theo pháp luật và chỉ đạo hiện hành. Trường hợp này, Bên B phải xin trước việc kiểm tra thống nhất và quyết định từ Bên A.

**ĐIỀU 5 : ĐỊA CHỈ NHẬN THÔNG BÁO**

Sửa đổi Điều khoản số 20 trong bản hợp đồng cũ ký kết ngày 01/03/2011 thành Điều khoản số 5 trong bản hợp đồng mới, gồm các nội dung như sau :

- **Bên A:** Địa chỉ vẫn giữ nguyên, đã được nêu rõ trong bản hợp đồng ban đầu ký kết ngày 01/03/2011
- **Bên B:**
- Trụ sở chính : Nhà số 7B, Đường số 466, Phường Tonle Basak, Quận Chamka Mon, Thủ đô Phnom Penh, Vương Quốc Campuchia (Văn phòng đại diện VRG)
- Số điện thoại : (855) 972680495
- Chi nhánh văn phòng : Ấp Chon Khlo, Xã 2 Thnu, Huyện Snuol, Tỉnh Kratie, Vương Quốc Campuchia.
- Số điện thoại : 0977339977
- Email : boretchan@gmail.com

Trường hợp có thay đổi địa chỉ nêu trên, Bên thay đổi địa chỉ liên lạc phải báo tin cho bên còn lại được biết trước ít nhất 30 (ba mươi) ngày, trước khi thay đổi địa chỉ.

**ĐIỀU 6:**

Bên B chịu trách nhiệm quản lý, giữ gìn và bảo vệ khu đất đường đi, sông ngòi, núi non nằm trong khu vực tô nhượng đất kinh tế đã được phân định cho Công ty thuê, nhằm mục đích giữ gìn là đất công của Nhà nước.

**ĐIỀU 7:**

Ngoài các Điều khoản nêu trên, các Điều khoản khác trong hợp đồng đã được ký kết vào ngày 01/03/2011 vẫn giữ nguyên và vẫn giữ nguyên hiệu lực thi hành.

**ĐIỀU 8:**

Hai bên phải chịu trách nhiệm thi hành theo các Điều khoản hiện hành trong bản hợp đồng được ký kết vào ngày 01/03/2011 cùng với các điều khoản sửa

đổi trong bản hợp đồng mới này, hợp đồng sửa đổi hợp đồng bắt đầu có hiệu lực kể từ ngày ký và phải tiếp tục thực hiện theo mọi Chủ trương, chính sách của Chính phủ Hoàng gia Campuchia.

*Làm tại Phnom Penh, ngày 27 tháng 06 năm 2017*

| **BÊN A**<br>**BỘ TRƯỞNG BỘ NÔNG, LÂM VÀ NGƯ NGHIỆP** | **BÊN B**<br>**CÔNG TY TRÁCH NHIỆM HỮU HẠN PHÁT TRIỂN CAO SU DẦU TIẾNG(CAMBODIA) DACAMRUCO** |
|---|---|
| *(Đóng dấu và ký tên)* | *(Đóng dấu và ký tên)* |
| **VENG SAKHUN** | **TRỊNH VĂN HOÀNG** |

**Nơi lưu trữ tài liệu:**

- Văn phòng Hội đồng Bộ trưởng
- Bộ Kinh tế và Tài chính
- Hội đồng phát triển Campuchia
- Bộ Tư pháp
- Tòa hành chính Tỉnh Kratie
- Chánh văn phòng rừng cây
- Tổng cục Nông nghiệp
- Vụ Kế hoạch và Thống kê
- Vụ Nông-Công nghiệp
- Sở Nông, Lâm và Ngư nghiệp Tỉnh Kratie
- Bên A
- Bên B
- Tài liệu – Niên đại

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
# ស្តីពី
# ការកែតម្រូវកិច្ចសន្យាចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១
# រវាង
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# និង
# ក្រុមហ៊ុន ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ)

- យោងកិច្ចសន្យាចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ) ស្តីពីការវិនិយោគដាំដំណាំកៅស៊ូ ដែលមានទីតាំងស្ថិតនៅស្រុកស្នួល និងស្រុកឆ្លូង ខេត្តក្រចេះ
- អនុលោមតាមប្រការ១៨ នៃកិច្ចសន្យាចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ) ស្តីពីការវិនិយោគដាំដំណាំកៅស៊ូ ដែលមានទីតាំងស្ថិតនៅស្រុកស្នួល និងស្រុកឆ្លូង ខេត្តក្រចេះ
- យោងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ នឹងនេសាទ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុន ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ) ចំនួន ១៩ច្បាប់
- យោងលិខិតលេខ៩២៧ សជណ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ ដូចខាងក្រោម ៖

**ប្រការ១** : ត្រូវបានកែសម្រួលចំណុច១.១ ក្នុងប្រការ១ នៃកិច្ចសន្យាដើមចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ មកជាប្រការ១ថ្មី ទៅជាកម្មវត្ថុនៃកិច្ចសន្យានេះ ភាគី "ក" យល់ព្រមផ្តល់ដីសម្បទានសេដ្ឋកិច្ចដែលមានផ្ទៃក្រឡាសរុបចំនួន ២ ៥៤៩,៨០ (ពីរពាន់ប្រាំរយសែសិបប្រាំបួន ក្បៀស ប៉ែតសិប) ហិកតា ជាផ្ទៃដីត្រូវបានចុះបញ្ជីដីរដ្ឋរួចរាល់មានទីតាំងស្ថិតនៅស្រុកស្នួល និង

ស្រុកឆ្លូង ខេត្តក្រចេះ ជូនភាគី "ខ" កាន់កាប់ប្រើប្រាស់សម្រាប់ធ្វើការវិនិយោគដាំដំណាំកៅស៊ូ។ ទំហំផ្ទៃដីនេះបានបញ្ជាក់ច្បាស់លាស់ ក្នុងគំនូសផែនទីចង្អុលទីតាំងនិងបញ្ជីចំណុចនិយាមកា ដែលចាប់ពីពេលនេះតទៅហៅថា "ទីតាំង" និងមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុភ្ជាប់ជាមួយជាឧបសម្ព័ន្ធ នៃកិច្ចសន្យាកែតម្រូវនេះ។

**ប្រការ២** : ក្នុងអាណត្តិនៃកិច្ចសន្យានេះ បន្ថែមលើខ្លឹមសារនៃប្រការទាំងឡាយដែលមានចែងក្នុងកិច្ចសន្យានេះ ភាគី "ខ" មានកាតព្វកិច្ចដូចខាងក្រោម ៖

**២.១-** ត្រូវរៀបចំផែនការមេទៅតាមទំហំផ្ទៃដីដែលមានចែងក្នុងប្រការ១ថ្មី យ៉ាងយូររយៈពេល ០៣ (បី) ខែ បន្ទាប់ពីចុះកិច្ចសន្យាកែតម្រូវនេះទៅ។ កម្មវិធីប្រើប្រាស់ដីថ្មីនឹងត្រូវអនុវត្តទៅតាមផែនការមេ ដែលផែនការមេនេះត្រូវមាន៖ កម្មវិធីប្រើប្រាស់ទីតាំង ការប្រើប្រាស់បច្ចេកទេសផ្សេងៗ និងគុណភាពនៃផែនការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្នុងកិច្ចដំណើរការអភិវឌ្ឍន៍គម្រោងវិនិយោគ។ ភាគី "ខ" អាចចាប់ផ្តើមដំណើរការបានលុះត្រាតែមានការយល់ព្រមលើឯកសារផែនការមេពីភាគី "ក" ជាមុនសិន។

**២.២-** ដើម្បីឲ្យមានប្រសិទ្ធភាពលើកិច្ចដំណើរការគម្រោងវិនិយោគ ក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច និងធានាបានលើការគ្រប់គ្រង ការត្រួតពិនិត្យវាយតម្លៃ ភាគី "ខ" ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំឲ្យបានច្បាស់លាស់។ ផែនការសកម្មភាពនេះត្រូវបញ្ជូនជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យបានមុន ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃដែលក្រុមហ៊ុនស្នើសុំឈូសឆាយដាំដុះក្នុងអនុតំបន់បន្តបន្ទាប់។

**ប្រការ៣** : **អំពីថិរវេលា**

ត្រូវបានកែសម្រួលប្រការ៥ចាស់ នៃកិច្ចសន្យាដើមចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ មកជាប្រការ៣ថ្មី ដែលមានខ្លឹមសារដូចខាងក្រោម ៖

**៣.១-** កិច្ចសន្យានេះមានរយៈពេល៥០ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា នៃកិច្ចសន្យាដើមចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១។ សេចក្តីជូនដំណឹងបញ្ចប់កិច្ចសន្យាត្រូវផ្តល់ជាមុនចំនួន ០១ (មួយ) ឆ្នាំ ឬនៅក្នុងឆ្នាំចុងក្រោយ នៃកិច្ចសន្យា។

**៣.២-** ភាគី "ខ" មានសិទ្ធិសុំបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេល៥០ឆ្នាំ។ ក្នុងរយៈពេល០១ឆ្នាំមុនពេលផុតកំណត់កិច្ចសន្យា ភាគី "ខ" អាចស្នើសុំធ្វើវិនិយោគបន្តទៅទៀត ហើយការបន្តអាចធ្វើទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា តាមសំណើរបស់ភាគី "ក" ដោយយោងទៅតាមការអនុវត្តកន្លងមករបស់ភាគី "ខ" ការអនុវត្តន៍នៃទីតាំងសម្បទានដីសេដ្ឋកិច្ច ផលប្រយោជន៍សេដ្ឋកិច្ច សង្គមកិច្ច របស់ភាគីទាំងពីរ និងដោយមានការសិក្សា និងឯកភាពពីភាគី "ក" អំពីល័ក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី។ ក្នុងករណី

មិនមានការសុំបន្តកិច្ចសន្យានេះទេ ភាគី "ក" មានសិទ្ធិផ្តល់កិច្ចសន្យាវិនិយោគជូនទៅភាគីផ្សេងទៀត។

**ប្រការ៤ : ការផ្ទេរ**

ត្រូវបានកែសម្រួលប្រការ១០ចាស់ នៃកិច្ចសន្យាដើមចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ មកជាប្រការ៤ថ្មី ដែលមានខ្លឹមសារ ដូចខាងក្រោម ៖

ភាគី"ខ" ពុំអាចផ្ទេរកិច្ចសន្យាទៅតតីយបុគ្គលបានឡើយ លើកលែងមានការអនុញ្ញាតតាមច្បាប់ និងបទបញ្ញានានារបស់រាជរដ្ឋាភិបាល។ ប៉ុន្តែភាគី "ខ" អាចសហការទុនវិនិយោគជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលដទៃទៀត ដោយផ្អែកទៅតាមច្បាប់ និងបទបញ្ញាជាធរមាន។ ករណីខាងលើនេះ ភាគី"ខ" ត្រូវសុំការឯកភាពពិនិត្យ និងសម្រេចជាមុនសិនពីភាគី "ក" ។

**ប្រការ៥ : អាសយដ្ឋានសម្រាប់ការជូនដំណឹង**

ត្រូវបានកែសម្រួលប្រការ២០ចាស់នៃកិច្ចសន្យាដើមចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ មកជាប្រការ៥ថ្មី ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ភាគី "ក" ៖ រក្សាទុកនៅដដែលដូចកិច្ចសន្យាដើមចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១។
- ភាគី "ខ" ៖

ស្នាក់ការកណ្តាល ៖ ផ្ទះលេខ៧បេ ផ្លូវលេខ៤៦៦ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា (ការិយាល័យតំណាង VRG)

ទូរស័ព្ទលេខ ៖ (៨៥៥) ៩៧ ២ ៦៨០ ៥៩៥

ស្នាក់ការសាខា ៖ ភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ៖ ០៩៧ ៧ ៣៣៩ ៩៧៧

អ៊ីម៉ែល ៖ boretchan@gmail.com

ក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋានជូនដំណឹងខាងលើនេះ ភាគីដែលមានប្តូរអាសយដ្ឋានត្រូវជូនដំណឹងទៅភាគីមួយទៀតឲ្យបានយ៉ាងតិច៣០ (សាមសិប)ថ្ងៃ មុននឹងធ្វើការផ្លាស់ប្តូរ។

**ប្រការ៦ :** ភាគី "ខ" ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងថែរក្សាការពារ ផ្លូវ ស្ពាន អូរ ស្ទឹង និងភ្នំ ស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនដែលត្រូវបានកាត់ចេញ ដើម្បីរក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

**ប្រការ៧** : ក្រៅពីប្រការខាងលើ ប្រការផ្សេងៗទៀត នៃកិច្ចសន្យាចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ នៅរក្សា និងនៅមានសុពលភាពដដែល។

**ប្រការ៨** : ភាគីទាំងពីរត្រូវទទួលខុសត្រូវចំពោះការអនុវត្តប្រការទាំងឡាយ ដែលស្ថិតជាធរមាន នៃកិច្ចសន្យាចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ និងកិច្ចសន្យាកែសម្រួលថ្មីនេះ ដែលចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ និងបន្តអនុវត្តតាមរាល់គោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៧

**ភាគី "ក"**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ភាគី "ខ"**

**ក្រុមហ៊ុន ដូវទៀង (ខេមបូឌា) រ៉ាប់បើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ)**

Trinh Van Hoang

**កន្លែងតម្កល់ឯកសារ ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងយុត្តិធម៌
- សាលាខេត្តក្រចេះ
- រដ្ឋបាលព្រៃឈើ
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានកសិ-ឧស្សាហកម្ម
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ
- ភាគី "ក"
- ភាគី "ខ"
- ឯកសារ កាលប្បវត្តិ